01354274

002/19-09-2007-ECCC/TC
E1/461

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 30 / 11 / 2016
ម៉ោង (Time/Heure) : 13 : 30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

**<u>កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី</u>**

**<u>សាធារណៈ</u>**

សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសង

ថ្ងៃ ចន្ទ ទី ២២ ខែ សីហា ឆ្នាំ ២០១៦

**សវនាការលើភ័ស្តុតាង - ថ្ងៃ ៤៤២**

រៀបចំដោយ៖ លោកស្រី សែ កុលទុន្នី និង កញ្ញា Maddalena GHEZZI

| **<u>កំណត់ហេតុអ្នកចូលរួម</u>** |
|---|
| ចំពោះមុខ ចៅក្រម យ៉ា សុខន (ប្រធាន), ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា, ចៅក្រម Claudia FENZ, ចៅក្រម ធូ មណី |
| ចៅក្រមបំរុង៖ ចៅក្រម Martin KAROPKIN |
| ក្រឡាបញ្ជី៖ លោកស្រី សែ កុលវុន្នី, កញ្ញា Maddalena GHEZZI |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក សេង លាង, លោក Nicholas KOUMJIAN, លោក Dale LYSAK |
| ជនជាប់ចោទ៖ លោក នួន ជា (ពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ), លោក ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក លីវ សុវណ្ណា, លោកស្រី Doreen CHEN |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោកស្រី Anta GUISSÉ, លោក គង់ សំអុន |
| ក្រុមមេធាវីប្រចាំការសម្រាប់ជនជាប់ចោទ ខៀវ សំផន៖ លោកស្រី ទូច វល័ក្ស, លោក Calvin SAUNDERS |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោក ពេជ អង្គ, លោកស្រី Marie GUIRAUD |
| ដើមបណ្តឹង/សាក្សី/អ្នកជំនាញ៖ 2-TCW-850, អ៊ុំ យឿន (2-TCCP-274) |

| |
|---|
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អរុណ |
| ផ្សេងៗ៖ លោក កែវ វ៉ាត, លោក វ៉ាត សុម៉ៅ, កញ្ញា ស្រី ណាក់, លោក ឡុញ ង៉ែត, លោកស្រី ពេជ ចរិយា, កញ្ញា McRae Alison DUNBAR |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៦ | ចាប់ផ្តើមម៉ោង៖ ០៩.០០ | បញ្ចប់ម៉ោង៖ ១៦.០០ |
| សម្រាកពេលព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.០៧ | បញ្ចប់ម៉ោង៖ ១០.២៧ |
| សម្រាកថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ ១១.៣១ | បញ្ចប់ម៉ោង៖ ១៣.២៨ |
| សម្រាកពេលរសៀល | ចាប់ផ្តើមម៉ោង៖ ១៤.៣៤ | បញ្ចប់ម៉ោង៖ ១៤.៥៧ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ០៤ ម៉ោង និង ១៩ នាទី |

**កិច្ចដំណើរការនីតិវិធីផ្សេងទៀត**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការប្រកាសបើកកិច្ចដំណើរការសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី | អង្គជំនុំជម្រះ<br>ក្រឡាបញ្ជី | ០៩.០១ | ០៩.០៣ |
| សំណើរបស់ នួន ជា ស្នើសុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ | មេធាវីការពារក្តី នួន ជា | ០៩.០៣ | ០៩.០៦ |
| ការតាំងសំណួរទៅកាន់សាក្សី (2-TCW-850) | អង្គជំនុំជម្រះ<br>សហព្រះរាជអា<br><br>ជ្ញា<br>មេធាវីការពារក្តី នួន ជា<br>មេធាវីការពារក្តី ខៀវ សំផន | ០៩.០៦<br>០៩.១៥<br>១៣.៥១<br>១៤.៥៧ | ០៩.១៥<br>១៣.៥១<br>១៤.៣៣<br>១៥.២៣ |
| ការធ្វើសេចក្តីសន្និដ្ឋានទាក់ទងនឹងវិសាលភាពនៃបទរំលោភសេពសន្ថវៈ (E306/7, E307/7/1) | មេធាវីការពារក្តី ខៀវ សំផន<br>សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី | ០៩.២១<br>០៩.២៣ | ០៩.២៣<br>០៩.២៥ |
| ការតាំងសំណួរទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណី (2-TCCP-274) | អង្គជំនុំជម្រះ<br>មេធាវីនាំមុខតំណាងដើម | ១៥.២៤<br>១៥.៣៤ | ១៥.៣៤<br>១៥.៥៨ |

| | បណ្តឹងរដ្ឋប្បវេណី | | |
|---|---|---|---|

**<u>សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖</u>**

**<u>ការប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការនិងការប្រកាសពីវត្តមានរបស់ភាគី</u>**

ប្រធានអង្គជំនុំជម្រះប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ។ ក្រឡាបញ្ជីរាយការណ៍ថា គ្រប់ភាគីទាំងអស់មានវត្តមាន លើកលែងតែមេធាវីការពារក្តី នួន ជា លោក លីវ សុវណ្ណា អវត្តមានដោយមូលហេតុផ្ទាល់ខ្លួន។ ជនជាប់ចោទ នួន ជា មានវត្តមាននៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។

**<u>សំណើរបស់ នួន ជា សុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ</u>**

អង្គជំនុំជម្រះសម្រេចអនុញ្ញាតតាមសំណើរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំលះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការនីតិវិធីដោយផ្ទាល់ក្នុងសាលសវនាការ និងអនុញ្ញាតឱ្យគាត់តាមដានកិច្ចដំណើរការនីតិវិធីសវនាការពីបន្ទប់ឃុំខ្លួនស្ថិតនៅខាងក្រោមសាលសវនាការ។

**<u>ការតាំងសំណួរទៅកាន់សាក្សី</u>** <u>2-TCW-850</u>

អង្គជំនុំជម្រះបានប្រកាសផ្អែកតាមឯកសារ E319/35 ដែលថា សាក្សី 2-TCW-850 ជាសាក្សីប្រភេទ ក ដែលត្រូវប្រើប្រាស់នៅឈ្មោះរហស្សនាមក្នុងកិច្ចដំណើរការនីតិវិធី។ បន្ទាប់មក ប្រធានបានតាំងសំណួរបឋមមួយចំនួន និងប្រាប់អំពីសិទ្ធិ និងករណីយកិច្ចរបស់សាក្សីដល់សាក្សី ហើយសហព្រះរាជអាជ្ញា មេធាវីការពារក្តី នួន ជា និងមេធាវីការពារក្តី ខៀវ សំផន បានតាំងសំណួរទៅកាន់សាក្សី (2-TCW-850)។

**<u>ការធ្វើសេចក្តីសន្និដ្ឋានទាក់ទងនឹងវិសាលភាពនៃបទរំលោភសេពសន្ថវៈ</u>**

មេធាវីការពារក្តី ខៀវ សំផន បានស្នើឱ្យអង្គជំនុំជម្រះចេញសេចក្តីសម្រេចលើវិសាលភាពនៃបទរំលោភសេពសន្ថវៈឱ្យបានឆាប់ ដើម្បីឱ្យភាគីមានពេលវេលាសម្រាប់រៀបចំការសួរដេញដោលសាក្សីទាំងនោះ។ មេធាវីនាំមុខតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងថា សារណារបស់ពួកគេនៅក្នុងសំណើ E306/7 គឺកម្រិតត្រឹមតែស្នើឱ្យអង្គជំនុំជម្រះធ្វើការបញ្ជាក់ទាក់ទងនឹងមន្ទីរសន្តិសុខ-ស២១, មន្ទីរសន្តិសុខក្រាំងតាចាន់ និងសហករណ៍ត្រាំកក់ ។

**<u>ការតាំងសំណួរទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ យឿន</u>** <u>2-TCCP-274</u>

អង្គជំនុំជម្រះបានប្រកាសផ្អែកតាមឯកសារ E319/35 ដែលថា ដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-274 ជាសាក្សីប្រភេទ ក ដែលត្រូវប្រើប្រាស់នៅឈ្មោះរហស្សនាមក្នុងកិច្ចដំណើរការនីតិវិធី។ ក្រោយមកមន្ត្រីច្បាប់នៅការិយាល័យសហចៅក្រមស៊ើបអង្កេត បានជូនដំណឹងមកអង្គជំនុំជម្រះថា ដើមបណ្តឹងរូបនេះលែងចាត់ទុកជាសាក្សីប្រភេទ ក ហើយ គឺអាចប្រើប្រាស់ឈ្មោះបាននៅពេលសវនាការជាសាធារណៈ។

ប្រធានអង្គជំនុំជម្រះបានតាំងសំណួរបឋមមួយចំនួនទៅដើមបណ្តឹងរដ្ឋប្បវេណី បន្ទាប់មកមេធាវីដើមបណ្តឹងរដ្ឋប្បវេណី បានតាំងសំណួរទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ យឿន 2-TCCP-274។

Re-Classified Documents

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/9517 | E319/19.3.86 | 00980361-00980377, 99984868-00984883, 00998275-00998286 | Written Record of Interview of [redacted] | C | 00890370 | 00984877 | 00998281 |
| E3/2073 | / | 00055162-00055218, 00876379-00876440, 00184136-00184139, 00892841-00892890 | DC-Cam Statement of SAU Ren | P | 00055197, 00055201 | 00876419, 00876423-00876424 | 00892873, 00892872 |

Other documents (No Change)

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/9570 | E319/19/19.3.75 | 00893174-00893177, 00901042-00901046, 00974985-00974988 | Written record of witness interview of [redacted] | C | 00893175 00893176 | 00901043 00901044 | 00974986 |
| E3/9149R | / | T01227022-T01227022 | Recording of Interview of [redacted] | C | 18:35-18:58; 49:00-51:41; 51:41-52:23; 27:15 | | |
| E3/9587 | E319.1.18 | 00997020- | Written | C | 00997052 | 01000693 | 01050295 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | 00997060, 01000663-01000700, 01050266-01050303 | Record of Interview of [redacted] Dated 19-06-2014 | | | | |
| E3/35 | D166/166 | 00340559-00340578, 00346145-00346162, 00367717-00367734 | Written Record of Interview of KE Pich Vannak | P | 00340565 | 00346152 | 00367723 |
| E3/375 | D166/177 | 00348789-00348805, 00360749-00360764, 00369912-00369926 | Written Record of Interview of BAN Siek | P | 00348800 | 00360759 | 00369922 |
| E3/4202 | / | 00858214-00858410, 00920122-00920144, 00757471-00757568, 00849349-00849484 | Book by GINA Chon and THET Sambath entitled "Behind the Killing Fields: A Khmer Rouge Leader and one of his Victims" | P | 00858335-00858336 | 00757529-00757530, | 00847432 |
| E3/5293 | D166/175 | 00348838-00348847, 00351699-00351708 | Written Record of Interview of [redacted] | C | 00348845 00348842-00348843, 00348844 | 00351705-00351706, 00351703, | 00367752, 00367749, 00367751 |
| E3/10634 | / | 01136636-01136641, 01151274-01151279 | Written Record of Interview witness [redacted] | C | 01136640-011366541 | 01151278 | / |
| E3/6011 | D22/511 | 00496717-00496725, 00891277, 01306494, 00890596, 01303327-01303329 | Civil party application [redacted] 09-VU-01594 | C | 00496717 | / | / |

| **ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖** |
|---|
| • អនុញ្ញាតឱ្យជនជាប់ចោទ នួន ជា បន្តតាមដានកិច្ចដំណើរការនីតិវិធីសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ហើយបង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា ដើម្បីបន្តសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។ (០៩.០៣) |
| • បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឱ្យនាំខ្លួនពួកគាត់ត្រឡប់មកកាន់សាលសវនាការវិញឱ្យបានមុនម៉ោង ៩.០០ ព្រឹក នៅថ្ងៃ អង្គារ៍ ទី ២៣ ខែ សីហា ឆ្នាំ ២០១៦។ (១៥.៥៩) |

| **កាលវេលាសវនាការបន្ត** |
|---|
| សវនាការនឹងបន្តទៅថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ ចាប់ផ្តើមពីម៉ោង ០៩.០០ ព្រឹក។ |

ភ្នំពេញ ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៦

ក្រឡាបញ្ជី ក្រឡាបញ្ជី

លោកស្រី សែ សុមុនីដា Maddalena GHEZZI

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE